# មតិអារម្ភកថា
# របស់ឯកឧត្តម ជា សំអាង អនុប្រធានរដ្ឋបាលព្រៃឈើ
# និងជាប្រធានក្រុមការងារកាត់បន្ថយការបញ្ចេញឧស្ម័នដែលបណ្តាលមកពីការបាត់បង់ និងរេចរឹលព្រៃឈើប្រទេសកម្ពុជា (ក្រុមការងារ REDD+ កម្ពុជា)

## ក្នុងពិធីបិទអង្គសិក្ខាសាលាស្តីអំពី
## ការជ្រើសរើសក្រុមប្រឹក្សាយោបល់សម្រាប់ការងារ REDD+ កម្ពុជា

(សណ្ឋាគាររ៉ាហ្វល់ឡឺរ៉ូយ៉ាល់ភ្នំពេញ ថ្ងៃទី២៩ - ៣០ ខែតុលា ឆ្នាំ២០១៣)

- *សូមគោរព គណៈអធិបតី ឯកឧត្តម លោក លោកស្រី ជាតំណាងដៃគូអភិវឌ្ឍន៍*
- *សូមគោរព លោក លោកស្រី ជាតំណាងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ*
- *សូមគោរព លោក លោកស្រី ជាតំណាងសង្គមស៊ីវិល និងជនជាតិដើមភាគតិច*
- *លោក លោកស្រី ជាមន្ត្រីរាជការ និងសមាជិក សមាជិកានៃអង្គសិក្ខាសាលាទាំងមូលជាទីរាប់អាន*

*ក្នុងនាមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានរដ្ឋបាលព្រៃឈើ និងជាប្រធានក្រុមការងារ REDD+ កម្ពុជា និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសំដែងនូវសេចក្តីសោមនស្សរីករាយក្រៃលែង ដែលបានចូលរួមក្នុងពិធីបិទអង្គសិក្ខាសាលាស្តីអំពី ការជ្រើសរើសក្រុមប្រឹក្សាយោបល់សម្រាប់ការងារ REDD+ កម្ពុជា នាពេលនេះ។*

*ដោយបានចូលរួមក្នុងដំណើរការនៃអង្គសិក្ខាសាលា ខ្ញុំបានកត់សម្គាល់ឃើញថា អង្គសិក្ខាសាលាយើងនេះ មានសកម្មភាពរស់រវើក ប្រកបដោយការចូលរួមដ៏សស្រាក់សស្រាំ។ ក្នុងកិច្ចពិភាក្សា សិក្ខាកាមទាំងអស់ បានផ្តល់មតិយោបល់ ចូលរួមយ៉ាងផុលផុសក្នុងន័យស្ថាបនា និងប្រកបដោយការជឿជាក់។ ទោះបីជាសិក្ខាកាមទាំងអស់ អញ្ជើញមកពីបណ្តាភាគីអ្នកពាក់ព័ន្ធផ្សេងៗគ្នាក៏ដោយ ក៏ប៉ុន្តែក្នុងន័យទស្សនៈ និងគោលគំនិតសំខាន់ពាក់ព័ន្ធនឹងការបង្កើត ក្រុមប្រឹក្សាយោបល់សម្រាប់ការងារ REDD+ នៅកម្ពុជា បានបង្ហាញឲ្យឃើញថា ឯកឧត្តម លោក លោកស្រីមានការចុះសម្រុងនឹងឯកភាពគ្នា*

ជាពិសេសភាពចាំបាច់ តម្រូវឲ្យមានក្រុមប្រឹក្សាយោបល់ និងតួនាទីដ៏សំខាន់របស់ក្រុមនេះ ដែលមិនអាចខ្វះបាននៅក្នុងដំណើការត្រៀមលក្ខណៈសម្រាប់REDD+ នៅកម្ពុជា ដែលជាតំណាក់កាលដ៏សំខាន់ក្នុងការរៀបចំឲ្យមាន គោលនយោបាយ យុទ្ធសាស្ត្រ គោលការណ៍ណែនាំ និងក្របខ័ណ្ឌការងារនានាសម្រាប់REDD+ នៅកម្ពុជា ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ពាក់ព័ន្ធនឹងដំណើការជ្រើសរើស ខ្ញុំមានការចាប់អារម្មណ៍យ៉ាងខ្លាំងក្នុងការបង្កើតឲ្យមានគណៈកម្មការស្ម័គ្រចិត្ត ដែលមានសមាជិកមកពី អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ មានតួនាទីសំខាន់ ជាអ្នកសម្របសម្រួលជ្រើសរើសក្រុមប្រឹក្សាយោបល់។ នេះជាសក្ខីភាព បង្ហាញឲ្យឃើញយ៉ាងច្បាស់ ពីការចាត់ចែងឲ្យមានការចូលរួមពីអ្នកពាក់ព័ន្ធ ចូលរួមផ្តល់មតិយោបល់ និងសម្រេចចិត្តក្នុងដំណើការជ្រើសរើសនេះ។ ជាមួយគ្នានេះ ខ្ញុំសង្កេតឃើញថា គណៈកម្មការស្ម័គ្រចិត្តបានប្រើគ្រប់មធ្យោបាយក្នុងការផ្សព្វផ្សាយ និងលើកទឹកចិត្ត ដើម្បីឲ្យមានបេក្ខភាពតំណាងមានចំនួនគ្រប់គ្រាន់សម្រាប់ការជ្រើសរើស។ លើសពីនេះទៀត គណៈកម្មការស្ម័គ្រចិត្ត បានចាត់ចែងឲ្យមានការចូលរួមបោះឆ្នោតដោយផ្ទាល់ និងដោយប្រយោលតាមរយៈ ប្រព័ន្ធអ៊ីនធើណិត ក្នុងការជ្រើសរើសតំណាងរបស់ក្រុមនីមួយៗ ដើម្បីឲ្យតំណាងដែលបានជ្រើសរើសមានការទទួលស្គាល់កាន់តែទូលំទូលាយពីក្រុមរបស់ខ្លួន។

ដោយឡែកពីនេះ ដំណើការជ្រើសរើសតំណាងជនជាតិដើមភាគតិច គណៈកម្មការ ស្ម័គ្រចិត្តបានរៀបចំឲ្យមានការចុះទៅជ្រើសរើសតំណាងរបស់គាត់ ដល់មូលដ្ឋានខេត្តទាំង១៩ ដែលមានជនជាតិដើមរស់នៅ។ កិច្ចការងារនេះសបញ្ជាក់ឲ្យឃើញយ៉ាងច្បាស់ នូវការយកចិត្តទុកដាក់ជាពិសេសរបស់គណៈកម្មការស្ម័គ្រចិត្ត ចំពោះបងប្អូនជនជាតិដើមភាគតិច ដើម្បីធានាថាតំណាងដែលបានជ្រើសរើស មានការទទួលស្គាល់ពីគ្រប់ជនជាតិដើមភាគតិចក្នុងខេត្តនានា និងមានការគាំទ្រពីអង្គការសង្គមស៊ីវិល និងអាជ្ញាធរដែនដីនៅថ្នាក់ក្រោមជាតិ។

ខ្ញុំសូមគូសបញ្ជាក់ថា ដំណើការជ្រើសរើសក្រុមប្រឹក្សាយោបល់នេះ ពិតជាមានការចូលរួមអនុគ្គ ពីគ្រប់ភាគីអ្នកពាក់ព័ន្ធ ក្នុងការផ្តល់យោបល់ ពិភាក្សា និងការសម្រេចចិត្ត ប្រកបដោយតម្លាភាពនិងសមធម៌។

ពាក់ព័ន្ធនឹងលទ្ធផលនៃការជ្រើសរើស ខ្ញុំសង្កេតឃើញថា តំណាងរបស់ក្រុមនីមួយៗ សុទ្ធតែមានប្រវត្តិការងារច្រើនឆ្នាំ ពោរពេញទៅដោយសមត្ថភាពនិងបទពិសោធន៍។ ដូច្នេះ ខ្ញុំមានជំនឿដ៏មុតមាំថា តំណាងដែលបានជ្រើសរើសនឹងអាចបំពេញតួនាទី ក្នុងនាមជាក្រុមប្រឹក្សាយោបល់ ប្រកបដោយការទទួលខុសត្រូវខ្ពស់ ចំពោះបុព្វហេតុ និងផលប្រយោជន៍របស់ក្រុមផងខ្លួន។

- គណៈអធិបតី ឯកឧត្តម លោក លោកស្រី ជាទីគោរព

មុននឹងបញ្ចប់ ខ្ញុំសូមថ្លែងនូវអំណរគុណ ឯកឧត្តម អស់លោក លោកស្រី ដែលចំណាយពេលវេលារយៈពេល២ថ្ងៃ ចូលរួមក្នុងអង្គសិក្ខាសាលាដែលមានអត្ថន័យដ៏សំខាន់នេះ។ ជាពិសេស ខ្ញុំសូមសំដែងនូវអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះការខិតខំប្រឹងប្រែងប្រកបដោយការទទួលខុសត្រូវ របស់គណៈកម្មការស្ម័គ្រចិត្តសម្របសម្រួលការជ្រើសរើសក្រុមប្រឹក្សាយោបល់ មន្ត្រីគាំទ្រលេខាធិការដ្ឋាន អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដែលបានចូលរួមសម្របសម្រួល ធ្វើបទង្ហាញ ដឹកនាំកិច្ចពិភាក្សា ពន្យល់បកស្រាយឆ្លើយតបនឹងសំណួរ ដែលធ្វើឲ្យសិក្ខាសាលានេះ មានដំណើរការប្រព្រឹត្តទៅដោយភាពរលូន សម្រេចនូវលទ្ធផលដូចបានគ្រោងទុក។

នាទីបញ្ចប់នេះ ខ្ញុំសូមជូនពរគណៈអធិបតី ឯកឧត្តម អស់លោក លោកស្រី សមាជិក សមាជិកា នៃអង្គសិក្ខាសាលាទាំងមូល សូមទទួលបាននូវសេចក្តីសុខគ្រប់ប្រការ និងមានសុវត្ថិភាពភាពក្នុងការធ្វើដំណើរត្រឡប់ទៅកាន់លំនៅដ្ឋានវិញ និងសូមប្រកាសបិទអង្គសិក្ខាសាលា ចាប់ពីពេលនេះតទៅ។

**សូមអរគុណ**